ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ពុធ ៤ កើត ខែ អស្សុជ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៩*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីកិច្ចពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយឯកឧត្តម Saud F.M. Al Suwelim ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត ប្រចាំព្រះរាជាណាចក្រកម្ពុជា

នាព្រឹកថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានជួបពិភាក្សាការងារជាមួយឯកឧត្តម Saud F.M. Al Suwelim ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីតប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមាននិវេសនដ្ឋាននៅទីក្រុង ហាណូយ ប្រទេសវៀតណាម ។

នៅក្នុងជំនួបពិភាក្សានោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះឯកឧត្តម Saud F.M. Al Suwelim នាឱកាសដែលឯកឧត្តមត្រូវបានរដ្ឋាភិបាលនៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីតតែងតាំងជាឯកអគ្គរាជទូតប្រចាំព្រះរាជាណាចក្រកម្ពុជា ខណៈដែលប្រទេសទាំងពីរកម្ពុជា និងអារ៉ាប៊ីសាអូឌីត កំពុងរីតចំណងការទូត និងបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការដែលបាននាំមកនូវលទ្ធផលប្រកបដោយផ្លែផ្កាជាបន្តបន្ទាប់ ។ ចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃនេះនឹងកសាងជាមូលដ្ឋានគ្រឹះដ៏រឹងមាំ សម្រាប់បង្កើនវិសាលភាពពាណិជ្ជកម្ម និងការវិនិយោគរវាងប្រទេសទាំងពីរនាពេលអនាគត ។

ឯកឧត្តម Saud F.M. Al Suwelim ឯកអគ្គរាជទូតអារ៉ាប៊ីសាអូឌីតប្រចាំព្រះរាជាណាចក្រកម្ពុជា បានវាយតម្លៃខ្ពស់ ចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយចីរភាពក្នុងរយៈពេលជាងពីរទសវត្សកន្លងមក ។ លើសពីនេះ, កម្ពុជារក្សាបាននូវសុខសន្តិភាពនៅទូទាំងប្រទេស ប្រកបដោយវឌ្ឍនភាព និងវិបុលភាព ។ ឯកឧត្តមឯកអគ្គរាជទូតបានកត់សំគាល់ឃើញផងដែរថា នៅកម្ពុជា ប្រជាជនកាន់សាសនាអ៊ីស្លាមរស់នៅប្រកបដោយភាពសុខដុមរមនាជាមួយប្រជាជនកាន់សាសនាផ្សេងទៀត ដែលបានបង្ហាញពីការគោរពសិទ្ធិមនុស្ស និងសេរីភាពខាងជំនឿ និងសាសនាយ៉ាងទូលំទូលាយ ។

ជាមួយគ្នានេះ ឯកឧត្តមឯកអគ្គរាជទូតបានគូសបញ្ជាក់ថា មូលនិធិអារ៉ាប៊ីសាអូឌីតសម្រាប់ការអភិវឌ្ឍ (Saudi Fund for Development-SFD) នៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត មានបំណងផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការជាឥណទានសម្បទានជូនរាជរដ្ឋាភិបាលកម្ពុជា ដើម្បីយកទៅអនុវត្តគម្រោងសំដៅរួមចំណែកបង្កើនល្បឿននៃការអភិវឌ្ឍនៅកម្ពុជា ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានជម្រាបជូនឯកឧត្តមឯកអគ្គរាជទូតអារ៉ាប៊ីសាអូឌីតថា កន្លងទៅថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ ចក្ខុវិស័យវែងឆ្ងាយ និងគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវវិធានការកែទម្រង់គ្រប់ជ្រុងជ្រោយ ដើម្បីទាក់ទាញការវិនិយោគ សម្រួលពាណិជ្ជកម្ម និងជំរុញ សកម្មភាព សេដ្ឋកិច្ចនៅកម្ពុជា ។ ពេលនេះ គឺជាឱកាសដ៏មានសារៈសំខាន់ដែលវិនិយោគិនអារ៉ាប៊ីសាអូឌីតគួរមកស្វែងយល់អំពីកាលានុវត្តភាពវិនិយោគនៅកម្ពុជា ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** យល់ឃើញថា បច្ចុប្បន្ន វិសាលភាពនៃកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ កម្ពុជា និងអារ៉ាប៊ីសាអូឌីត នៅមិនទាន់ស័ក្តិសមជាមួយសក្តានុពលដែលប្រទេសទាំងពីរមាននៅឡើយ។ ដូចនេះ ប្រទេសទាំងពីរនៅមានកាលានុវត្តភាពជាច្រើនទៀតក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ ។ ក្នុងន័យនេះ ភាគីទាំងពីរបានឯកភាពជំរុញឱ្យមានការផ្លាស់ប្តូរទស្សនកិច្ចទៅវិញទៅមករវាងថ្នាក់ដឹកនាំទាំងកម្រិតនយោបាយ ទាំងកម្រិតបច្ចេកទេស ព្រមទាំងថ្នាក់ដឹកនាំធុរកិច្ច នៃប្រទេសទាំងពីរ ដើម្បីពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការឱ្យកាន់តែសកម្ម និងស៊ីជម្រៅថែមទៀត ។ ដោយឡែក ពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ភាគីទាំងពីរនឹងជំរុញកិច្ចសហប្រតិបត្តិការផ្នែកហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត និងមូលនិធិអារ៉ាប៊ីសាអូឌីតសម្រាប់ការអភិវឌ្ឍ ដែលមានបំណងផ្តល់ឥណទានសម្បទានជូនរាជរដ្ឋាភិបាលកម្ពុជា ។ នេះគឺជាប្រភពហិរញ្ញប្បទានថ្មីមួយទៀត សម្រាប់បំពេញតម្រូវការរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការជំរុញល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ច- សង្គម និងការកាត់បន្ថយភាពក្រីក្រ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបន្តពិភាក្សាជាមួយមូលនិធិអារ៉ាប៊ីសាអូឌីតសម្រាប់ការអភិវឌ្ឍ អំពីលក្ខខណ្ឌនៃឥណទាននេះ មុននឹងឈានទៅកំណត់វិស័យអាទិភាព និងលើកសំណើគម្រោង ដើម្បីឱ្យស្របតាមយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅធានាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនៅក្នុងរយៈពេលវែង និងមិនមានហានិភ័យបំណុល ។

ឆ្លៀតក្នុងឱកាសនោះដែរ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះរាជដ្ឋាភិបាលនិងប្រជាជនអារ៉ាប៊ីសាអូឌីត ដែលបានជួយឧបត្ថម្ភគាំទ្រដល់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ហើយជូនពរសូមឯកឧត្តមឯកអគ្គរាជទូតអារ៉ាប់ប៊ីសាអូឌីត Saud F.M. Al Suwelim បំពេញបេសកកម្មការទូតនៅកម្ពុជាប្រកបដោយជោគជ័យ ៕